# សិល្បៈ និងជំនឿប្រតិបត្តិចំពោះក្បាលទូកង

ក្បាលទូកង និយាយក្នុងពេលនេះសំដៅចំពោះទូកប្រណាំង ពោលគឺរាប់បញ្ចូល ទាំងទូកង(ទូកអុំ) និងទូកមួង(ទូកចែវ) ដែលបណ្ដាអ្នកស្រុករស់នៅតាមតំបន់ទន្លេតែងតែ ប្រើប្រាស់សម្រាប់ប្រណាំងតាមទម្លាប់ប្រពៃណី។ ក្បាលទូកងទាំងនេះ គឺជាផ្នែកដ៏សំខាន់ គួរចាប់អារម្មណ៍សិក្សាស្វែងយល់ ដ្បិតទាំងការរចនាផ្ចិតផ្ចង់ក្រៃលែង បង្ហាញឲ្យឃើញពី តម្លៃសិល្បៈខ្ពង់ខ្ពស់របស់អ្នកស្រុក ព្រមទាំងមានអត្ថន័យពាក់ព័ន្ធជំនឿទៀតផង។ ក្នុង វប្បធម៌ខ្មែរ ជាពិសេសក្នុងគំនិតអ្នកស្រុករស់នៅតាមដងទន្លេ ស្គាល់ច្បាស់ និងមានជំនឿ យ៉ាងមុតមាំចំពោះទូកទាំងនោះខ្លាំងណាស់។ នៅតាមសហគមន៍តំបន់ទន្លេភាគច្រើន គេ តែងសាងទូកងតម្កល់នៅវត្ត ទុកជាសម្បត្តិរួមរបស់ភូមិស្រុក។

ទូកងនីមួយៗតែងមានលក្ខណៈពិសេសផ្សេងៗគ្នា ទាំងជំនឿពាក់ព័ន្ធនិងលក្ខណៈ ជាក់ស្ដែងផ្នែកសិល្បៈ។ ទូកង(ឬទូកអុំ) ភាគច្រើនមានប្រវែងពី៣២ទៅ៣៦ ម៉ែត្រ សម្រាប់ ចំណុះទូកពី៦៥ទៅ៧៥នាក់។ ទូកមួង(ឬទូកចែវ) មានប្រវែងពី២៧ទៅ៣១ម៉ែត្រ សម្រាប់ ចំណុះទូកពី២៨ទៅ៤៨នាក់ ឬបច្ចុប្បន្នមានរហូតដល់៥០ទៅ៦០នាក់។ តាមទម្លាប់របស់ អ្នកស្រុក គឺចាប់ពីថ្ងៃភ្ជុំបិណ្ឌ វត្តនីមួយៗតែងធ្វើកិច្ចដាក់ទូកចុះទឹកហាត់សម ដើម្បីត្រៀម ប្រណាំងជាមួយទូកវត្តផ្សេងៗនៅក្នុងថ្ងៃភ្ជុំធំ ឬក្នុងថ្ងៃចេញព្រះវស្សា ឬថ្ងៃកឋិន (រូបលេខ ១-២)។ តាមការសង្កេតការប្រណាំងរបស់អ្នកស្រុក តែងធ្វើមុនព្រះរាជពិធីអុំទូកថ្នាក់ជាតិ ដ្បិតជាទូទៅគេតែងជ្រើសរើសយកទូកល្អៗ មកចូលរួមប្រណាំងនៅទន្លេចតុមុខ មុខព្រះ បរមរាជវាំងក្នុងរាជធានីភ្នំពេញ។



រូបលេខ១-២ ពិធីប្រណាំងទូកបណ្ដាវត្តនៅកោះដាច់ក្នុងថ្ងៃចេញព្រះវស្សា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ចំពោះក្បាលទូកង ជាផ្នែកចុងខាងមុខនៃទូក ដែលគេនិយមយកដើមខ្នុរ ឬដើមសំរោងមកធ្វើ។ ក្បាលទូកតែងលាបពណ៌ គូរក្បាច់លម្អ ធ្វាក់បំពាក់ភ្នែក បំពាក់ណា បំពាក់រំយោលសក់សងខាង ចងក្រណាត់ជាតីក្រហម(ឬពណ៌ផ្សេងៗ) និងដាក់ទ្វេងថ្វាយគ្រឿងសក្ការៈ។ ផ្នែកក្បាលទូកនេះ គេតែងថ្វាយក្ងស់ ទាំងពេលរក្សាទុកនៅក្នុងរោង និងពេលចុះទឹកសំចតមុន និងក្រោយអុំ (រូបលេខ២៣)។ ក្បាលទូក ក៏មានមុខងារដាក់ទ្វេងសម្រាប់អ្នករាំក្បាលទូក ឬអ្នកស្រុកខ្លះហៅថាអ្នកបូល ឬអ្នកទំក្បាល ដើម្បីរាំ ឬអង្គុយបញ្ជាទូកផងដែរ។ សូមបញ្ជាក់ថា អ្នកទំក្បាលទូកច្រើនតែបុរសវ័យចំណាស់ និងជាអ្នកដែលទទួលបានការគោរពស្រឡាញ់ពីប្រជាពលរដ្ឋក្នុងសហគមន៍ ចេះមើលបច្ចេកទេស និងបញ្ជាទូកបានល្អ (រូបលេខ២៤)។



រូបលេខ២៣ ការបូជាក្បាលទូកវត្តក្បាលកោះ



រូបលេខ២៤ អ្នកទំក្បាលឬអ្នកបូល(រូប៖ស៊ុំ កុសល)

ចំពោះការសាងក្បាលទូក អាចចាត់ទុកជាដំណាក់កាលសំខាន់មួយក្នុងចំណោមដំណាក់កាលផ្សេងទៀតនៃការសាងទូក។ ជាងទូក តែងរៀបចំធ្វាក់ក្បាលទូកបន្ទាប់ពីផែសាច់មាឌទូក ចាប់កុងត្រូវតាមខ្នាតរូបរាល់ ដ្បិតក្បាលទូកត្រូវលៃយ៉ាងណាឲ្យត្រូវលំនាំតួទូក និងឲ្យមើលឃើញអំណាច ត្រូវនឹងល្បឿនបច្ចេកទេស។ ជាទូទៅក្បាលទូកច្រើនធ្វើឲ្យងើបខ្ពស់ផុតទឹក និងមានស្រឡោកោជាកន្ទ្វេងអ្នកបូលអង្គុយ។ ប្រសិនបើទូកថ្មីត្រូវកសាងជំនួសទូកចាស់ គេតែងធ្វើកិច្ចបួងសួងសុំបារមីពីក្បាលទូកចាស់(រូបលេខ២៥-៦)។ នៅពេលបំពាក់ក្បាលទូក គេត្រូវថ្វាយភ្លេង បូជាគ្រឿងសក្ការៈ និងសំណែនផ្សេងៗ (រូបលេខ២៧)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩-៧ កិច្ចកសាងក្បាលទូក និងបំពាក់ក្បាលទូកថ្មី

ក្បាលទូកងត្រូវបានគូរលម្អដោយក្បាច់ភ្ញីវល្លិ៍ ឬក្បាច់អង្គរ ច្នៃរំលេចភ្ជាប់ដោយរូបក្បាលនាគ ឬម្ករ និងរូបតំណាងផ្សេងៗទៀតដូចជា ហនុមាន ទេវតា អ្នកតា សិង្ហ ឬបារមីនៃទូកនោះៗ បើពិនិត្យលម្អិតតែក្បាលទូកនោះទៀតសោត គេឃើញក្រៅពីមានឈ្មោះសម្គាល់ទូក មានភ្នែក មានសក់ និងតុបតែងលម្អផ្សេងៗ គេតែងឃើញមានថ្វាយគ្រឿងសក្ការៈដូចជា ធូប ទៀន ស្លាធម៌ បាយសី ក្រាស កញ្ចក់ ម្សៅ ក្រែមជាដើម ទាំងពេលរក្សា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ទុកក្នុងរោង និងពេលចុះទឹក។ អ្នកស្រុកយល់ថារាល់ទូកនីមួយៗតែងមានបារមី(អ្នកស្រុកខ្លះហៅថា "រក្សាទូក") ឬអមនុស្សថែរក្សា ជាពិសេសគឺមាន"ព្រាយ"កាន់ផង។[1] នៅចាំមើលថែរក្សាជានិច្ច។ មកដល់ចំណុចនេះ គេអាចពិចារណាចំណុចមួយចំនួនដូចជាឈ្មោះទូក ការតុបតែងលម្អ ដង្វាយគ្រឿងសក្ការៈ និងការថែរក្សាទុកដាក់។ ជាទូទៅ កាលដើមឡើយឈ្មោះទូក គឺច្រើនជាឈ្មោះវត្ត ឬបារមី ឬឈ្មោះអ្នកតា និងឈ្មោះតួអង្គក្នុងរឿងទេពកថាជាដើម(រូបលេខ៨-១១)។









*រូបលេខ៨-១១ ការរចនាលម្អក្បាលទូកជារូប ឬក្បាច់ និងថ្វាយគ្រឿងសក្ការបូជាផ្សេងៗចំពោះក្បាលទូក*

ដោយឡែក ក្រៅពីការគោរពបូជាអំឡុងពេលប្រើប្រាស់ នៅពេលផ្លាស់ប្តូរ ឬក្បាលទូកនោះពុកផុយខូចប្រើពុំកើតតទៅទៀត គេតែងយកទៅរក្សាទុកក្នុងខ្ទមអ្នកតា។ លើសពីនេះអ្វីដែលបង្ហាញឱ្យឃើញច្បាស់ពីទំនាក់ទំនងរវាងទូកនិងអ្នកតា គឺទូកខ្លះគេគូររូបតួអង្គអ្នកតានោះនៅក្បាលទូក ឬដាក់ឈ្មោះអ្នកតាភ្ជាប់នឹងទូកតែម្តង។ មកដល់ចំណុចនេះ

[1] Ang Chouléan 1986: 138-141

គេគួរចាំថាតាមទំនៀមបុរាណ លោកច្រើនដាក់ឈ្មោះទូកប្រណាំងពាក់ព័ន្ធនឹង "ស្រី" ព្រោះដោយជឿថាជា"រក្សាទូក" ឬជាអមនុស្សភេទស្រី(ព្រាយ) ដែលតាមថែរក្សាទូកដូចជា ស្រីខ្មៅ ស្រីស ស្រីស្រស់ ស្រីកែវស្រីស្រាវ នារីឧត្តម្ភ រស្មីនារី នារីរង្សី នារីរ័ត្នមានឫទ្ធិជាដើម។[2]




*រូបលេខ១២-១៤ អ្នកតា និងបំណែកក្បាលទូកចាស់ៗរក្សាទុកគោរពបូជា*

ក្នុងសៀវភៅបាត់ដំបងសម័យលោកម្ចាស់ របស់អ្នកនិពន្ធ តូច ឈួង[3] មានចំណុចមួយបានលើកឡើងអំពីភាពល្បីល្បាញនៃបារមីទូក ជាពិសេសទូកវត្តកណ្តឹង ក្នុងខេត្តបាត់ដំបងថា"[...]ទូកនីមួយៗសុទ្ធតែមានខ្មោចព្រាយបិសាចកាន់។ គេត្រូវតែគោរព ហើយប្រកាន់យ៉ាងតឹងរ៉ឹង។ ក្រោយពីពេលប្រណាំង គេត្រូវយកទូកនោះមកតម្កល់ក្នុងទីមួយសមគួរ ដូចជាក្រោមដើមពោធិ ឬដាក់ក្នុងរោង។ ពេលមុនយកទៅប្រណាំងត្រូវប្រារព្ធពិធីបួងសួងដោយមានសំណែន និងប្រគុំភ្លេងពិណពាទ្យ ឬភ្លេងសារិកាកែវ ទៅតាមទម្លាប់ ឬចំណង់របស់ព្រាយបិសាចដែលកាន់ទូកនោះ។ ទូកសព្រហ្មមាស របស់វត្តកណ្តឹងមានមហិទ្ធិរិទ្ធិណាស់។ នៅពេលបួងសួងមុនចុះទឹកទៅប្រណាំង ស្ត្រីមានផ្ទៃពោះដើរកាត់ត្រូវតែរលូតកូន។ លោកយាយ អុំ បានប្រាប់ថា គេត្រូវបួងសួងបីយប់បីថ្ងៃ ទើបគេរំកិលទូកសព្រហ្មមាសនេះលើកំណល់មូលឲ្យរអិលលើសំពត់កម្រាលពណ៌ស ទៅកាន់ស្ទឹងក្រោមស្នូរនៃភ្លេងពិណពាទ្យ ហើយមាននារីព្រហ្មចារីយ៍ពីរនាក់ស្លៀកពាក់តាមប្រពៃណីដង្ហែទៅផង។ តែបើរៀបចំពិធីមិនគ្រប់កិច្ចនោះទេ ទោះបីខំរុញយ៉ាងណាក៏ទូកមិនទៅមុខ

---

[2] យ៉ា ដា ១៩៩៥: ២៤

[3] បោះពុម្ពលើកទីផ្ទាំ១៩៧៤ លើកទីផ្ទាំ១៩៩៤។ ខ្លឹមសារសៀវភៅនេះធ្លាប់មានការសិក្សា និងបកប្រែជាភាសាបរទេសផង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដែរ។ [...]ទូកប្រណាំងសឹងតែទាំងអស់មានតំណមសំខាន់ម្យ៉ាង គឺគេមិនឲ្យប៉ះក្បាលទូក ឬជាន់ក្បាលទូក។ ទោះបីដោយចេតនា ឬអចេតនា អ្នកណាជាន់ក្បាលទូកប្រាកដជាត្រូវធ្លាក់។ ទូកឈ្មោះរថណាម របស់វត្តសំពៅមិនអនុញ្ញាតឲ្យមនុស្សពីរបីនាក់ជិះលេងទេ។ លោកតា ហ៊ិន ជាអាចារ្យវត្តគរបានមានប្រសាសន៍ថា បើត្រូវការអុំទូកវត្តរថណាមនេះ គេត្រូវចុះឲ្យគ្រប់ចំនួនគ្រប់ខ្នង់ ទើបអុំទៅមុខបាន បើមិនដូចនោះទេទូកនេះនឹងវិលត្រឡប់ត្រឡិន ធ្វើឲ្យអ្នកអុំធ្លាក់ក្នុងទឹកមិនខាន។ គាត់បានប្រាប់ទៀតថា ទូកវត្តតាមិមមួយមិនចាំឈ្មោះ អណ្តែតប្រាសទឹកពីវត្តតាមិមរហូតដល់វត្តខ្វែង”។

តាំងពីដើមរៀងមកគេតែងសង់រោងសមរម្យសម្រាប់រក្សាទុកទូកនៅក្បែរព្រះវិហារ ឬរក្សាទុកនៅសាលាបុណ្យ ដោយមានដាក់ផ្កាយគ្រឿងសក្ការៈផ្សេងៗរៀងរាល់ថ្ងៃសីល និងថ្ងៃបុណ្យតូចធំក្នុងវត្ត។ ក្នុងថ្ងៃអុំប្រណាំង ព្រះសង្ឃអង្គណាជាធំគង់ក្នុងវត្តសាមីទូកច្រើននិមន្តប្រស់ព្រំទូក និងចំណុះទូក។ ក្នុងពេលនោះ ទូកនីមួយៗគេមានតំណមតឹងរឹងណាស់ ពុំអនុញ្ញាតឲ្យចំណុះទូកផ្សេង ឬអ្នកខាងក្រៅឡើងជិះលេងផ្តេសផ្តាសឡើយ។ ក្រោយចប់អុំប្រណាំង គេដោះក្នែកទូករក្សាទុកនៅកន្លែងសមគួរ ឬទុកនៅមុខព្រះជីវ៍ក្នុងព្រះវិហារ។

## ឯកសារយោង


តូប ឈួង

១៩៩២, *បាត់ដំបងសម័យលោកម្ចាស់,* មជ្ឈមណ្ឌលបូព៌ា-បស្ចិម, រដ្ឋហាវ៉ៃ

យ៉ាង ដា

១៩៩៥, *ទូកប្រណាំងខ្មែរ,* សារណាបញ្ចប់បរិញ្ញាបត្រ មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

Ang Chouléan

1986, *Les êtres surnaturels dans la religion populaire khmère,* Cedoreck, Paris


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត